សាលាកប័ត្រព័ត៌មាន៖ កម្រងករណីសិក្សា៖ ការទិញសន្លឹកឆ្នោតក្នុងការបោះឆ្នោតព្រឹទ្ធសភា
កាលបរិច្ឆេទ៖ ខែកុម្ភៈ ឆ្នាំ២០១២
រូបភាពរួម៖ ការប៉ុនប៉ងទិញសន្លឹកឆ្នោតនាពេលថ្មីកន្លងទៅពីសមាជិកក្រុមប្រឹក្សាឃុំម្នាក់នៅខេត្តបាត់ដំបង ក្នុងការបោះឆ្នោតព្រឹទ្ធសភា គួសបញ្ហាក់ពីអំពើពុករលួយនៅក្នុងវិស័យនយោបាយនៃប្រទេសកម្ពុជា និងភាពខ្វះចន្លោះនៃច្បាប់ប្រឆាំងនឹងអំពើពុករលួយ។

សេចក្តីផ្តើម

ការប៉ុនប៉ងថ្មីៗដោយបុរសពីរនាក់ ក្នុងការទិញសន្លឹកឆ្នោតពីក្រុមប្រឹក្សាឃុំម្នាក់ នៅក្នុងការបោះឆ្នោតព្រឹទ្ធសភា បានគូសបញ្ជាក់ពីស្ថានភាពនៃអំពើពុករលួយនៅក្នុងវិស័យនយោបាយនៃព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”) និងការខកខានរបស់ស្ថាប័នរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហានេះ។ ជាដំបូងសាលាកប័ត្រនេះ បង្ហាញអំពីបញ្ហាដែលកើតមានឡើង មុននឹងធ្វើការសង្ខេបអំពីច្បាប់ជាតិ និងអន្តរជាតិ ដែលទាក់ទងទៅនឹងការទិញសន្លឹកឆ្នោត និងការខកខានរបស់ច្បាប់ជាតិដែលមានជាធរមាន ក្នុងការការពារជនណាដែលរាយការណ៍ពីអំពើពុករលួយ។ សាលាកបត្រ័មួយនេះត្រូវបានសរសេរដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលជាអង្គការ មិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ (“អង្គការ”) ដែលធ្វើការដើម្បីលើកកម្ពស់ និង ការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅក្នុងប្រទេសកម្ពុជា។

ការប៉ុនប៉ងទិញសន្លឹកឆ្នោត

នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១២ ក្រុមប្រឹក្សាឃុំ-សង្កាត់ ទូទាំងប្រទេសកម្ពុជា បានទៅបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា។ មុនការបោះឆ្នោតមួយសប្តាហ៍ សារព័ត៌មាន *ខឹម ភ្នំពេញប៉ុស្តិ៍* បានរាយការណ៍ថា បុរសពីរនាក់មកពីគណបក្សប្រជាជនកម្ពុជា បានទាក់ទងក្រុមប្រឹក្សាឃុំម្នាក់ មកពីគណបក្ស សម រង្ស៊ី ក្នុងក្រុងបាត់ដំបង ហើយបានប៉ុនប៉ងទិញសន្លឹកឆ្នោតពីសមាជិកក្រុមប្រឹក្សាម្នាក់នោះ (នៅថ្ងៃទី ២៥ខែមករា ឆ្នាំ២០១២ គណបក្ស សម រង្ស៊ី បានអះអាងថា គណបក្សដែលកាន់អំណាចជម្រុញឲ្យមានការទិញសន្លឹកឆ្នោត)។ អត្ថបទនេះបានរាយការណ៍ថា សមាជិកក្រុមប្រឹក្សា គណបក្ស សម រង្ស៊ី ម្នាក់បានថតសម្លេងបុរសទាំងពីរនោះ ដែលបានសន្យាឲ្យប្រាក់ខ្លួនចំនួន៧០០ដុល្លារ ដើម្បីជាថ្នូរនឹងការទទួលបានសន្លឹកឆ្នោតពីគាត់ រួមទាំងការឲ្យប្រាក់ជាមុនចំនួន ២០០ដុល្លារ។ ក្រោយមក សារព័ត៌មាន *ខឹ ភ្នំពេញប៉ុស្តិ៍* បានរាយការណ៍ថា សមាជិកក្រុមប្រឹក្សា គណបក្ស សម រង្ស៊ី ត្រូវបានកោះហៅឲ្យចូលទៅបំភ្លឺពីបទល្មើសថតសម្លេងការសន្ទនាជាលក្ខណៈឯកជន ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ (“អ្នកដែលត្រូវបានគេអះអាងថាប៉ុនប៉ងទិញសន្លឹកឆ្នោត បានដាក់ពាក្យប្តឹងភាគីម្ខាងទៀតពីបទថតសម្លេង” ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២”)។ ម្នាក់ក្នុងចំណោមសមាជិកគណបក្សប្រជាជនទាំងពីរ ដែលត្រូវបានថតសម្លេង ត្រូវបានពិន័យ ចំនួន១២៣០ ដុល្លារ ដោយគណៈកម្មាការរៀបចំការបោះឆ្នោតខេត្តបាត់ដំបង (នៅថ្ងៃទី ៣១ មករា ឆ្នាំ២០១២ សារពត៌មាន *ខឹ ភ្នំពេញប៉ុស្តិ៍* បានរាយការណ៍ថា គណបក្សសម រង្ស៊ី លើកឡើងថា ការពិន័យលើការទិញសន្លឹកឆ្នោតនេះនៅមានលក្ខណៈតិចតួចនៅឡើយ)។ មានការរាយការណ៍បន្ថែមទៀតថា បុគ្គលដែលមានពិរុទ្ធពីការទិញសន្លឹកឆ្នោត បានទាមទារប្រាក់ចំនួន២៤៧៥ដុល្លារ ពីសមាជិកក្រុមប្រឹក្សាគណបក្ស សម រង្ស៊ី ជាការសងជំងឺចិត្តដែលសមាជិកក្រុមប្រឹក្សានេះបានថតសម្លេងគាត់ដោយខុសច្បាប់ (“អ្នកប៉ុនប៉ងទិញសន្លឹកឆ្នោតមិនបានសម្រេច ចង់ទទួលបានការសងជំងឺចិត្ត ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១២)។ របាយការណ៍នេះមិនបានចង្អុលបង្ហាញថាតើ អង្គភាពប្រឆាំងអំពើពុករលួយមានអន្តរាគមន៍នៅក្នុងបញ្ហានេះដែរឬទេ។

អំពើពុករលួយក្នុងប្រទេសកម្ពុជា

អំពើពុករលួយជ្រាបចូលគ្រប់ទិដ្ឋភាពទាំងអស់ក្នុងជីវិតរស់នៅជាសាធារណៈក្នុងប្រទេសកម្ពុជា។ អង្គការតម្លាភាពអន្តរជាតិ បានធ្វើចំណាត់ថ្នាក់អំពើពុករលួយនៅប្រទេសកម្ពុជា នៅលេខរៀងទី១៥៤ ក្នុងចំណោមប្រទេស១៧៨ ក្នុងឆ្នាំ២០១០ ក៏ប៉ុន្តែកាលពីឆ្នាំ២០១១ ប្រទេសកម្ពុជាបានធ្លាក់ទៅលេខរៀងទី១៦៤ ក្នុងចំណោម១៨៣ ប្រទេសវិញ (បើទោះបីជា ពិន្ទុ ២.១ ដូចគ្នានឹងឆ្នាំ២០១០ក៏ដោយ)។ តាមរបាយការណ៍ស្តីពីសូចនករនៃពុករលួយសាកល ចេញផ្សាយនៅឆ្នាំ២០១០ ដោយអង្គការដដែលនេះ បានលើកឡើងថាមន្ត្រីតុលាការ ជាប់ចំណាត់ថ្នាក់លេខមួយ មន្ត្រីរាជការសាធារណៈជាប់ចំណាត់ថ្នាក់លេខពីរ និងគណៈបក្សនយោបាយនានាជាប់ចំណាត់លេខបី ខាងការប្រព្រឹត្តអំពើពុករលួយខ្លាំងជាងគេនៅកម្ពុជា។ ការទិញសន្លឹកឆ្នោតធ្វើឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំង ដោយសារតែប្រការធ្វើឲ្យប៉ះពាល់ ដល់សុច្ឆរិតភាពនៅក្នុងប្រព័ន្ធប្រជាធិបតេយ្យ ជាងអំពើពុករលួយទៅទៀត។

ច្បាប់ជាតិដែលពាក់ព័ន្ធ

យោងតាមមាត្រា៦០៥ នៃក្រមព្រហ្មទណ្ឌ ការសូកប៉ាន់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ (“ឬ មន្ត្រីរាជការ ឬក៏មន្ត្រីជាប់ឆ្នោត”) ឲ្យធ្វើ ឬមិនធ្វើអ្វីមួយទៅតាមអ្វីដែលពួកគេចង់បាន គឺជាបទល្មើសមួយ។ ក៏ជាបទល្មើសផងដែរ ចំពោះមន្ត្រីដែលទទួលយកសំណូក (មាត្រា៥៩៤ នៃក្រមព្រហ្មទណ្ឌ)។ បទល្មើសទាំងពីរនេះត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ។ បន្ថែមលើការអនុវត្តន៍ច្បាប់ អង្គភាពប្រឆាំងអំពើពុករលួយ មានសិទ្ធិ

បើយោងតាមច្បាប់ស្តីពីការបោះឆ្នោតសមាជិករដ្ឋសភា ត្រូវចាត់ទុកថាមានទោសចំពោះណា ដែលផ្តល់សម្ភារៈ ឬក៏រង្វាន់ជាទឹកប្រាក់ ដើម្បីប្តូរយកសន្លឹកឆ្នោត។ ហើយបំរាមនេះក៏ធ្វើឡើងក្នុងការបោះឆ្នោតព្រឹទ្ធសភា (ដូចដែលមានចែងក្នុងមាត្រា ៣៣ នៃច្បាប់ស្តីពីការបោះឆ្នោតព្រឹទ្ធសភា) ក៏ដូចជាបទល្មើសព្រហ្មទណ្ឌដែលចែងដោយក្រមព្រហ្មទណ្ឌ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចពិន័យជាប្រាក់ពី ៥.000.000 ដល់២៥.000.000 រៀល មោឃភាពបេក្ខភាព និង/ឬ លុបឈ្មោះភាគីមានពិរុទ្ធចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត និងបញ្ជីអ្នកឈ្មោះឲ្យគេបោះឆ្នោត។

ច្បាប់អន្តរជាតិដែលពាក់ព័ន្ធ

ប្រទេសកម្ពុជា គឺជារដ្ឋហត្ថលេខីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលសង្កត់ធ្ងន់ទៅលើសិទ្ធិបោះឆ្នោតជាលក្ខណៈប្រជាធិបតេយ្យ ដែលត្រូវធ្វើឡើងដោយសេរី និងជាសម្ងាត់។ លើសពីនេះទៅទៀត កម្ពុជា ក៏បានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ។ អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ បង្ហាញពីលក្ខន្តិកៈប្រយុទ្ធប្រឆាំងអំពើពុករលួយ ដែលរួមមាន មាត្រា៨ ដែលផ្តល់អនុសាសន៍ថា រដ្ឋជាភាគីត្រូវបង្កើតវិធានការ និងប្រព័ន្ធនានា ដែលជួយសម្រួលដល់មន្ត្រីរាជការក្នុងការរាយការណ៍ពីសកម្មភាពពុករលួយទៅដល់អាជ្ញាធរដែលមានសមត្ថកិច្ច។

ភាពខ្វះចន្លោះនៅក្នុងច្បាប់ជាតិត្រូវបានលាតត្រដាង

បើទោះបីជា មាត្រា១៣ នៃច្បាប់ប្រឆាំងអំពើពុករលួយ ចែងថា ស្តាប័នប្រឆាំងអំពើពុករលួយត្រូវ "ចាត់វិធានការចាំបាច់ដើម្បីធានារក្សាសន្តិសុខ ដល់បុគ្គលដែលផ្តល់ព័ត៌មានទាក់ទងនឹងអំពើពុករលួយ " ដែលឆ្លុះបញ្ចាំងពី (ដោយផ្នែក) មាត្រា៨ នៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ វិធានការទាំងអស់នេះមិនបានពិពណ៌នា និងគ្មានការការពារ ឬផ្តល់អភ័យឯកសិទ្ធិដល់បុគ្គលដែលរាយការណ៍ពីអំពើពុករលួយឡើយ។ ផ្ទុយទៅវិញ មាត្រា៤១ ចែងថាត្រូវចាត់ទុកថាមានទោសពី "ការផ្តល់ពត៌មានមិនពិត.....កាលបើអំពើនេះនាំឲ្យធ្វើការស្រាវជ្រាវដោយឥតប្រយោជន៍"។ ប្រការនេះមានភាពមិនច្បាស់លាស់ ថាតើអ្នករាយការណ៍នឹងមានពិរុទ្ធចំពោះបទល្មើសនេះដែរ ឬយ៉ាងណា បើគ្រាន់តែពួកគេផ្តល់នូវពត៌មានមិនត្រឹមត្រូវ ដោយខ្លួនគិតមិនដល់អំពីភាពមិនប្រាកដប្រជានៃព័ត៌មាននោះ។ ជាងនេះទៅទៀត ចេតនាក្នុងការប្រព្រឹត្តសំណុក គឺមិនអាចជៀសផុតពីការធ្វើជាលក្ខណៈឯកជន និងជាសម្ងាត់នោះទេ ហើយអ្វីដែលសំខាន់នោះមានភស្តុតាងតិចតួចណាស់ដែលគេអាចរកបាន លើកលែងតែសក្ខីកម្មរបស់អ្នកប្តឹង។ ទោះជាយ៉ាងណាក៏ដោយ ឧទាហរណ៍នៃករណីខេត្តបាត់ដំបង បង្ហាញពីមនុស្សម្នាក់ដែលមានបំណងប្រមូលភស្តុតាង ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ ដែលធ្វើឲ្យគាត់ងាយត្រូវបានគេចោទពីបទរំលោភច្បាប់ឯកជនភាព។ កង្វះខាតការការពារដោយច្បាប់ចំពោះការផ្តន្ទាទោសបែបនេះ និងភាពមិនច្បាស់លាស់ក្នុងការប្រព្រឹត្តចំពោះអ្នកដាក់ពាក្យបណ្តឹង ដែលការលើកឡើងរបស់គាត់គឺគេមិនអាចរកឃើញ គឺជាកត្តាដែលនាំឲ្យមានការបង្អាក់ទឹកចិត្តដល់អ្នកដែលមានបណ្តឹងត្រឹមត្រូវ និងច្បាស់លាស់ពីបទល្មើសនៃអំពើពុករលួយមិនហ៊ានរាយការណ៍ពីអំពើនេះ។ នេះក៏ផ្តល់ឱកាសដល់គណបក្សកាន់អំណាចក្នុងការប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនទៅលើស្តាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធដទៃទៀត ក្នុងការកំណត់រកមុខបុគ្គលណាដែលរាយការណ៍អំពីអំពើពុករលួយដើម្បីផ្តន្ទាទោស ហើយផ្ទុយទៅវិញសកម្មភាពពុករលួយត្រូវបានគេមើលរំលង។

សេចក្តីសន្និដ្ឋាន

ជារឿងមួយដែលគួរឲ្យព្រួយបារម្ភ ចំពោះបុគ្គលដែលរាយការណ៍ពីអំពើពុករលួយមកពីគណបក្ស សម រង្ស៊ី ប្រឈមនឹងការស៊ើបអង្កេត និងការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ចំពោះសកម្មភាពប្រមូលភស្តុតាងលើករណីពុករលួយ ខណៈពេលដែលអង្គភាពប្រឆាំងអំពើពុករលួយមិនបានចូលរួមដោះស្រាយ ហើយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាអ្នកចេញមុខពិន័យប្រាក់បុរសម្នាក់ ក្នុងចំណោមពីរនាក់មកពីគណបក្សប្រជាជនកម្ពុជា ដែលត្រូវបានថតសម្លេង។ ការបំបាត់អំពើពុករលួយ ជាពិសេសស្ថិតក្នុងបរិបទនៃការបោះឆ្នោត គឺមានសារៈសំខាន់ចំពោះការបង្កើតឲ្យមានលទ្ធិប្រជាធិបតេយ្យមួយដែលមានដំណើរការដ៏ត្រឹមត្រូវ។ ដោយសារអំពើពុករលួយរីករាលដាលយ៉ាងធ្ងន់ធ្ងរនៅក្នុងលំហានយោបាយ ហើយដើម្បីរក្សាសុចរិតភាពក្នុងការបោះឆ្នោត និងប្រព័ន្ធប្រជាធិបតេយ្យនៅកម្ពុជា នោះជាការសំខាន់ណាស់ដែលតួអង្គមួយចំនួនដូចជាអង្គភាពប្រឆាំងអំពើពុករលួយ តុលការ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលជាអ្នកទទួលខុសត្រូវអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ ត្រូវដើរតួនាទីឲ្យមានប្រសិទ្ធិភាព ផ្តល់ភាពជឿជាក់ និងមិនប្រកាន់បក្សពួក ដើម្បីឆ្លើយតបទៅនឹងករណីជាក់ស្តែងនៃការទិញសន្លឹកឆ្នោត។ ច្បាប់ប្រឆាំងអំពើពុករលួយ គួរតែត្រូវបានគេធ្វើវិសោធនកម្ម ដើម្បីឲ្យស្របទៅនឹងអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ និងដើម្បីធានាឲ្យមានការការពារ និងអភ័យឯកសិទ្ធិបុគ្គលទាំងអស់ដែលមានភាពសុចរិតក្នុងការផ្តល់ភស្តុតាងពីអំពើពុករលួយ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង លោក អ៊ូ វីរៈ (លេខទូរស័ព្ទ +៨៥៥ (0) ១២ ៤០ ៤០ ៥១ ឬតាមរយៈអ៊ីម៉ែល ouvirak@cchrcambodia.org) ឬ John Coughlan (លេខទូរស័ព្ទ +៨៥៥ (0) ៨៩ ៥៨ ៣៥ ៩០ ឬតាមរយៈអ៊ីម៉ែល johncoughlan@cchrcambodia.org)